# បេឡាជាតិសន្តិសុខសង្គម

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែ

លេខ៖៤




## មាតិកា

### ព្រឹត្តិការណ៍សំខាន់ៗ


➤ ព្រឹត្តិការណ៍សំខាន់ៗ.......................................................២


### ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន


➤ ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.............២០


### សេវាផ្តល់ព័ត៌មានតាមទូរសព្ទ (Hotline)


➤ របៀបប្រើប្រាស់ ការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) .....................២៤



## រចនាសម្ព័ន្ធព្រឹត្តិបត្រ
## ខែកញ្ញា ឆ្នាំ២០២៥

**ឯកឧត្តម ម៉េង ហុង**
**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តមបណ្ឌិត **ហេង សុផាន់ណារិទ្ធ** |
| **និពន្ធនាយក** | លោក **អ៊ុក សំអូន** |
| **និពន្ធនាយករង** | លោកស្រី **ចាន់ ស៊ីណូន** |
| | លោក **ឃុន វិចិត្រ** |
| **លេខានិពន្ធ** | លោក **យន គន្ធា** |
| | លោក **យង់ សុខន** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **អ៊ុង ស៊ីខឿ** |
| | អ្នកស្រី **ទុិត បញ្ញា** |



សូមអានបន្តនៅទំព័រទី២



© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# អគារពិគ្រោះជំងឺ ប.ស.ស. នៃមន្ទីរពេទ្យកាល់ម៉ែត ត្រូវបានសម្ពោធប្រើប្រាស់ជាផ្លូវការ

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារពិគ្រោះជំងឺ ប.ស.ស. នៃមន្ទីរពេទ្យកាល់ម៉ែត ដែលមានកម្ពស់ ២ជាន់ មានបណ្តោយប្រវែង ៣០,៣៦ម៉ែត្រ ទទឹង ៦,២៥ម៉ែត្រ និងផ្ទៃក្រឡាសរុប ៥៦៩,០៤ ម៉ែត្រក្រឡា ដែលមានបន្ទប់សម្រាកព្យាបាលសរុបចំនួន ២០បន្ទប់ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

អគារពិគ្រោះជំងឺ ប.ស.ស. ដែលសម្ពោធប្រើប្រាស់ជាផ្លូវការ គឺជាការពង្រីកទីតាំងផ្តល់សេវាកាន់តែទូលាយ ឆាប់រហ័ស ដែលអាចជួយសម្រួលដល់បងប្អូនប្រជាពលរដ្ឋ ពិសេសការផ្តល់សេវាពិគ្រោះជំងឺក្រៅជូនអ្នកជំងឺប្រើប្រាស់ប័ណ្ណសមាជិក ប.ស.ស. បានកាន់តែច្រើនជាងមុនបន្ថែមទៀត ដែលជាចក្ខុវិស័យ របស់ក្រសួងសុខាភិបាល ដើម្បីឆ្ពោះទៅរកការសម្រេចបានតាមចក្ខុវិស័យសុខភាពកម្ពុជាឆ្នាំ២០៣០ គឺ «សម្រេចភាពធន់នៃប្រព័ន្ធសុខាភិបាល និងការគ្របដណ្តប់សុខភាពជាសកល ដែលធានាកម្ពុជាមានសុវត្ថិភាព និងសុខភាពល្អ»។

គួរឱ្យដឹងផងដែរថា បច្ចុប្បន្នសមាជិក ប.ស.ស. ដែលមកទទួលសេវាពិគ្រោះជំងឺក្រៅ នៅមន្ទីរពេទ្យកាល់ម៉ែត្រ មានប្រមាណជាមធ្យម ៨០០នាក់ ដល់១ ៤០០នាក់ ក្នុង១ថ្ងៃ ហើយបន្ទាប់ពីអគារពិគ្រោះជំងឺ ប.ស.ស. ដាក់សម្ពោធប្រើប្រាស់ជាផ្លូវការ នឹងអាចជួយកាត់បន្ថយការកកស្ទះក្នុងការមកទទួលសេវារបស់បងប្អូន និងបញ្ហាប្រឈមមួយចំនួនផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញចូលរួមកិច្ចពិភាក្សាស្តីពី ការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព

## កម្រងរូបភាពសកម្មភាព




នារសៀលថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមប្រជុំពិភាក្សា ជាមួយអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួន ៤រួមមាន៖ (១).ពិភាក្សាអំពីយន្តការនៃការជំរុញការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាពជាងមុន (២).ការពិនិត្យខ្លឹមសារ និងគំរូស្ទីកគ័របិទសម្គាល់រថយន្តដឹកជញ្ជូនកម្មករនិយោជិត (៣).ពិភាក្សាអំពីយន្តការនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត(៤).ពិភាក្សាអំពីយន្តការនៃការប្រឡងផ្តល់បណ្ណបើកបរដល់អ្នកបើកបររថយន្តដឹកជញ្ជូនកម្មករនិយោជិត។

កិច្ចប្រជុំពិភាក្សាខាងលើ ធ្វើឡើងនៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ដែលដឹកនាំដោយ **លោកជំទាវ មីន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និង **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ីម យ៉ាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងមានការអញ្ជើញចូលរួមពីភាគីពាក់ព័ន្ធប្រមាណជា ២០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ ចាត់ទុកគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាឃាតករលាក់មុខ

## កម្រងរូបភាពសកម្មភាព







គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាឃាតករលាក់មុខដែលធ្វើឱ្យមនុស្ស ស្លាប់ របួស និងពិការ ដែលបានបន្សល់ទុកនូវសោកនាដកម្មដ៏ធំ ដែលជាផលប៉ះពាល់ ដល់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិទាំងមូល។ នេះជាការថ្លែងឡើងពីសំណាក់ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ក្នុងឱកាសអញ្ជើញជាសហអធិបតីក្នុងពិធីអប់រំផ្សព្វផ្សាយ "ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរ និងសុវត្ថិភាពក្នុងការដឹកជញ្ជូន" ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករ និងកម្មករនិយោជិត នាព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ នៅតំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុបភ្នំពេញ។

**ឯកឧត្តមប្រធានក្រុមការងារ** បានឱ្យដឹងថា គិតចាប់ពីដើមឆ្នាំ២០២៥ រហូតដល់ខែសីហា ឆ្នាំ២០២៥ ករណីគ្រោះថ្នាក់ចរាចរណ៍លើរថយន្តដឹកកម្មករនៅទូទាំងប្រទេសមានចំនួន ៧ករណី និងបណ្តាលឱ្យមានជនរងគ្រោះសរុបចំនួន ១៦៤នាក់ ស្រី ១៣៨នាក់ ស្លាប់ ២នាក់ របួសធ្ងន់ ១៥នាក់ និងរបួសស្រាល ១៤៥នាក់។

**ឯកឧត្តមប្រធានក្រុមការងារ** បានបន្តថា ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ទាំងនេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម បានចុះផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរ និងសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូន ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិត ចំនួន ២៣៩លើក ដោយមានអ្នកចូលរួម ៦៥ ៤៩១នាក់ ស្រី ៥១ ៨២៩នាក់ (ចាប់ពីដើមឆ្នាំ២០២៥ រហូតដល់ខែសីហា ឆ្នាំ២០២៥)។

ក្នុងឱកាសជាមួយគ្នានេះ **ឯកឧត្តម សុខ ពេញវុធ** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ តំណាង **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានសំណូមពរដល់ម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ ក្នុងតំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុបភ្នំពេញ ត្រូវជំរុញ លើកទឹកចិត្ត និងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់កម្មករនិយោជិត ដែលកំពុងបំពេញការងារនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានរបស់ខ្លួន ឱ្យចូលរួមផ្សព្វផ្សាយបន្តពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពក្នុងពេលធ្វើដំណើរ ឱ្យបានកាន់តែច្រើនបន្ថែមទៀត ដើម្បីចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍មកនៅកម្រិតទាបបំផុត៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំពិភាក្សារវាង ប.ស.ស. ជាមួយអង្គការ ILO-BFC និង AIPF លើ គម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោក របស់បងប្អូនកម្មករនិយោជិត

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារជាមួយលោកស្រី ហ្វ្រោកខ្ជិស ប៊ូឡឺ (Froukje Boele) ប្រធានគម្រោងកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ (ILO-BFC) និងតំណាងអង្គការមូលនិធិបង្ការរបួសអាស៊ីប្រចាំនៅកម្ពុជា (AIPF) លើគម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ (Road Safety Project in the GFT Sector) នៅស្នាក់ការកណ្ដាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំនេះ បានពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួន២ រួមមាន៖ (១).ឈ្វេងយល់អំពីរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ក្រុមការងារ ស.ផ.ក នៃ ប.ស.ស. (២).ចែករំលែកអំពីគោលបំណង នៃគម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ (Road Safety Project in the GFT Sector) និងស្វែងរកកិច្ចសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគម្រោង។

តាមរយៈកិច្ចប្រជុំពិភាក្សានេះ **ឯកឧត្តមបណ្ឌិត**ប្រធានក្រុមការងារ បានបង្ហាញអំពីលទ្ធផល និងសកម្មភាពការងារសំខាន់ៗ ក្នុងការងារអាទិភាពរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ និងបានរៀបចំយន្តការសម្របសម្រួលរវាងតំណាងអ្នកបើកបររថយន្តដឹកជញ្ជូនកម្មករនិយោជិត តំណាងនិយោជក និងតំណាងកម្មករនិយោជិត ដើម្បីជំរុញការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមផែនការអាទិភាពរបស់រាជរដ្ឋាភិបាល។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ថ្នាក់ដឹកនាំ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមពិធីបុណ្យកាន់បិណ្ឌទី៩ នៅវត្តឃ្មួញ ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃអង្គារ ទី១៦ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកក្រោមឱវាទ បានចូលរួមពិធីបុណ្យកាន់បិណ្ឌទី៩ និងប្រគេនទេយ្យទានដល់ព្រះសង្ឃដែលគង់នៅវត្តឃ្មួញ ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ គឺជាពិធីបុណ្យមួយ ដែលធំជាងគេ នៅក្នុងចំណោមពិធីបុណ្យទាំងអស់ក្នុងប្រទេសកម្ពុជា ដែលប្រារព្ធធ្វើឡើងចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៥រោច ខែភទ្របទ ជារៀងរាល់ឆ្នាំ ហើយពុទ្ធសាសនិក តែងនាំគ្នាទៅធ្វើបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ នៅតាមទីវត្តអារាមនានាផងដែរ។

តាមទំនៀមទម្លាប់របស់ប្រជាជនខ្មែរ ក្នុងអំឡុងពេល១៥ថ្ងៃ នៃពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ គឺត្រូវតែទៅវត្តឱ្យបានម្តងយ៉ាងតិច ក្នុងថ្ងៃណាមួយមិនអាចខកខានបានឡើយ ពិសេសថ្ងៃ ១៥រោច ដែលជាថ្ងៃបង្ហើយ ដែលគេហៅថា "ភ្ជុំបិណ្ឌ"៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើនីតិវិធីនៃការចុះបញ្ជីសហគ្រាសនិងកម្មករនិយោជិត និងការបង់ភាគទានមកក្នុង ប.ស.ស. ត្រូវបានបិទបញ្ចប់ដោយជោគជ័យ

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើនីតិវិធីនៃការចុះបញ្ជីសហគ្រាស និងកម្មករនិយោជិត និងការបង់ភាគទានមកក្នុងបេឡាជាតិសន្តិសុខសង្គម បានបិទបញ្ចប់ដោយជោគជ័យ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ក្នុងឱកាសថ្លែងបិទសិក្ខាសាលានេះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានអរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាងក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងសមាគម ទាំងអស់ដែលបានចូលរួមផ្តល់ជាធាតុចូលយ៉ាងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាថ្មីនេះ។

**ឯកឧត្តមបណ្ឌិត** បានគូសបញ្ជាក់ថា ធាតុចូលគន្លឹះទាំងនេះ នឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការកែលម្អប្រព័ន្ធចុះបញ្ជីសហគ្រាស និងកម្មករនិយោជិត និងការបង់ភាគទាន ឱ្យកាន់តែមានភាពងាយស្រួល ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តមបណ្ឌិត** បានបន្តទៀតថា ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យានេះ គឺដើម្បីធានាថា គ្រប់កម្មករនិយោជិតទាំងអស់ ត្រូវទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមពេញលេញ ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំពិភាក្សារវាង ប.ស.ស. ជាមួយអង្គការ ILO-BFC និង AIPF លើ គម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោក របស់បងប្អូនកម្មករនិយោជិត

## កម្រងរូបភាពសកម្មភាព














តបតាមការអញ្ជើញពីសំណាក់ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** Mohammed Azman Bin Dato' Aziz Mohammed ប្រធានសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) និងជានាយកប្រតិបត្តិអង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូ ប.ស.ស. អញ្ជើញចូលរួមសន្និសីទសន្តិសុខសង្គមអាស៊ានឆ្នាំ២០២៥ ក្រោមមូលបទ "ការជំរុញចល័តភាព នៃអត្ថប្រយោជន៍របបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសក៍នៅក្នុងតំបន់អាស៊ាន" រៀបចំដោយអង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី ប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និបាតគូឡាឡាំពួរ ទីក្រុងគូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី។

សន្និសីទសន្តិសុខសង្គមអាស៊ានឆ្នាំ២០២៥ គឺជាវេទិកាដ៏មានសារៈសំខាន់ ដែលរៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំស្ថាប័នសន្តិសុខសង្គមថ្នាក់តំបន់ និងអ្នករៀបចំគោលនយោបាយ ដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីចល័តភាព នៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍នៅក្នុងតំបន់អាស៊ាន ដែលជាគំនិតផ្តួចផ្តើមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងន័យពង្រឹងកិច្ចសហការរវាងស្ថាប័នសន្តិសុខសង្គមក្នុងតំបន់ ក៏ដូចជាស្វែងរកយន្តការនានាដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ក្របខ័ណ្ឌឌីជីថល និងកម្រិតស្ថាប័ន ក្នុងន័យជំរុញចល័តភាព នៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍នៅក្នុងតំបន់។

នៅក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** ក៏បានអញ្ជើញជាវាគ្មិនកិត្តិយសធ្វើបទបង្ហាញក្រោមប្រធានបទ "ការឈ្វេងយល់អំពីសេចក្តីថ្លែងការណ៍អាស៊ាន និងគោលការណ៍ណែនាំអាស៊ានស្តីពី ចល័តភាព នៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍នៅក្នុងតំបន់អាស៊ាន"។

សូមបញ្ជាក់ផងដែរថា សន្និសីទសន្តិសុខសង្គមអាស៊ានឆ្នាំ២០២៥ មានការអញ្ជើញចូលរួមពីស្ថាប័នសន្តិសុខសង្គមអាស៊ានចំនួន ២០ស្ថាប័ន ដែលជាសមាជិក នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA)៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំទ្វេភាគីរវាង ប.ស.ស. កម្ពុជា និងអង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី ចែករំលែកបទពិសោធន៍ ស្តីពី ការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គម

## កម្រងរូបភាពសកម្មភាព












នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានគណៈកម្មការសម្របសម្រួលគម្រោង SASI តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយអង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី ដើម្បីចែករំលែកបទពិសោធស្តីពី ការពង្រីកវិសាលភាពគ្របដណ្តប់សន្តិសុខសង្គម ប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និបាតគូឡាឡាំពួរ ទីក្រុងគូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី។

កិច្ចប្រជុំ រៀបចំឡើងក្នុងគោលបំណងដើម្បីឈ្វេងយល់អំពីគោលនយោបាយជាយុទ្ធសាស្ត្រ និងនវានុវត្តន៍ របស់អង្គភាពសន្តិសុខសង្គម (SOCSO) នៃប្រទេសម៉ាឡេស៊ី ពាក់ព័ន្ធនឹងការពង្រីកវិសាលភាពការគ្របដណ្តប់របបសន្តិសុខសង្គម ដល់ក្រុមគោលដៅស្ថិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនបទ និងពិភាក្សាអំពីបញ្ហាប្រឈម ព្រមទាំងដំណោះស្រាយក្នុងការអនុវត្តរបបសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព។

ក្នុងឱកាសជាមួយគ្នានេះ ភាគីកម្ពុជាបានបង្ហាញពីវឌ្ឍនភាព នៃការអនុវត្តសន្តិសុខសង្គម ជាពិសេសការខិតខំប្រឹងប្រែងពង្រីកការគ្របដណ្តប់របបសន្តិសង្គម ដល់ក្រុមគោលដៅ ដើម្បីឈានដល់ការគ្របដណ្តប់សុខភាពជាសកល។ ជាមួយគ្នានេះ ភាគីម៉ាឡេស៊ីក៏បានចែករំលែក និងផ្លាស់ប្តូរបទពិសោធ ឧត្តមានុវត្តន៍ និងដំណោះស្រាយចំពោះបញ្ហាដែលខ្លួនជួបប្រទះ ក្នុងការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមផងដែរ។

កិច្ចប្រជុំទ្វេភាគីនេះមានការចូលរួមពីតំណាងសរុបចំនួន ១៦ រូប ដែលបានផ្តល់ឱកាសល្អសម្រាប់ប្រទេសទាំងពីរក្នុងការរៀនសូត្រពីគ្នា ដើម្បីអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមឱ្យកាន់តែប្រសើរឡើងនាពេលអនាគត៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអុកស្វាម បន្តសហការ រៀបចំវេទិកាថ្នាក់តំបន់ស្តីពី គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាននៅកម្ពុជា នៅខេត្តកំពង់ស្ពឺ

## កម្រងរូបភាពសកម្មភាព













នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តម ប៉ែន នរៈឧុធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េខ ហុខ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីបើកវេទិកាថ្នាក់តំបន់ស្តីពី គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាននៅកម្ពុជា ដោយមានការអញ្ជើញចូលរួមជាសហាធិបតីពីសំណាក់ **លោកជំទាវ គា សុត្ន** អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងមានការអញ្ជើញចូលរួមពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម តំណាងអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ថ្នាក់ដឹកនាំសហគមន៍ តំណាងកម្មករនិយោជិត ព្រមទាំងភាគីពាក់ព័ន្ធសរុបប្រមាណជា ២០០រូប ប្រព្រឹត្តទៅនៅសណ្ឋាគារ ផាមរីវើ ខេត្តកំពង់ស្ពឺ ។

មានប្រសាសន៍បើកវេទិកាថ្នាក់តំបន់នេះ **ឯកឧត្តមអគ្គនាយករង** បានថ្លែងឡើងថា ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអុកស្វាមបានសហការរៀបចំវេទិកានេះឡើង ដើម្បីពង្រឹងកិច្ចសហការ និងគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា តាមរយៈកិច្ចសន្ទនាសង្គម ដោយផ្តោតលើការឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណើនានា រវាងនិយ័តករ និងប្រតិបត្តិករសន្តិសុខសង្គម ជាមួយនឹងថ្នាក់ដឹកនាំសហគមន៍ និងតំណាងកម្មករនិយោជិត ដើម្បីស្តាប់កង្វល់ សំណើ និងចងក្រងធាតុចូលនានា ដែលជាឧត្តមប្រយោជន៍ដល់ការតាក់តែង គោលនយោបាយ ក្នុងន័យធានាគាំពារសង្គមសម្រាប់ទាំងអស់គ្នា ដើម្បីអន្តរកាលប្រកបដោយយុត្តិធម៌នៅកម្ពុជា។

តាមរយៈវេទិកា **ឯកឧត្តមអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំសហគមន៍ តំណាងកម្មករនិយោជិត តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្ត អ្នកឯកទេស អ្នកតាក់តែងគោលនយោបាយ ក៏ដូចជាថ្នាក់ដឹកនាំសហគមន៍ និងតំណាងកម្មករនិយោជិតមកពីគ្រប់វិស័យ នឹងប្តេជ្ញាចិត្តរួមគ្នា ធ្វើឱ្យប្រើសើរឡើងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា សម្រាប់បងប្អូនកម្មករនិយោជិត ជាពិសេសសម្រាប់កម្មករនិយោជិតជាស្ត្រីក្នុងវិស័យកសិ-ស្បៀងអាហារផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំស្តីពី "ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់បេឡាជាតិសន្តិសុខសង្គម សម្រាប់ការិយបរិច្ឆេទ ២០២៤ និងឆ្នាំពាក់ព័ន្ធ"

## កម្រងរូបភាពសកម្មភាព



**ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំនាយកដ្ឋានជំនាញ ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអាជ្ញាធរសវនកម្មជាតិ ស្តីពី "ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ការិយបរិច្ឆេទ ២០២៤ និងឆ្នាំពាក់ព័ន្ធ" នាព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ នៅសាលប្រជុំនាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ប.ស.ស. ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស, នាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ និងអង្គភាពសវនកម្មផ្ទៃក្នុងនៃ ប.ស.ស. សរុបប្រមាណជាង ២៥រូប។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូសវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ដែលបានអញ្ជើញមក ប.ស.ស. ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ការិយបរិច្ឆេទ ២០២៤ និងឆ្នាំពាក់ព័ន្ធ។

បន្ថែមពីលើនេះទៅទៀត **ឯកឧត្តមអគ្គនាយករង** ប.ស.ស. ក៏បានស្នើសុំនាយកដ្ឋានជំនាញទាំងពីរ និងអង្គភាពសវនកម្មផ្ទៃក្នុងនៃប.ស.ស. ចូលរួមសហការ ជាមួយគណៈប្រតិភូសវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ក្នុងការផ្តល់ទីកន្លែង ឯកសារ ព័ត៌មានពាក់ព័ន្ធផ្សេងៗ ឱ្យបានទាន់ពេលវេលា ដើម្បីឱ្យការធ្វើសវនកម្មនេះ ដំណើរទៅយ៉ាងរលូន និងសម្រេចបានជោគជ័យ។

សូមបញ្ជាក់ថា អាជ្ញាធរសវនកម្មជាតិ មានកាតព្វកិច្ចធ្វើសវនកម្មលើគ្រប់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងរដ្ឋបាលមូលដ្ឋាន គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. សហការ ជាមួយអង្គការអន្តរជាតិការងារ បើកវគ្គបណ្តុះបណ្តាលស្តីពីម៉ូដែលសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន រយៈពេល ៣ថ្ងៃ នៅទីស្នាក់ការកណ្តាល ប.ស.ស.

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃចន្ទ ទី៨ ខែកញ្ញា ឆ្នាំ២០២៥ **ឯកឧត្តម ឃុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី ម៉ូដែលសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន (ILO-Pens Modelling) ក្រោមការគាំទ្ររបស់អង្គការអន្តរជាតិខាងការងារ (ILO) ដឹកនាំដោយ **លោក** Kenichi Hirose ជំនាញការជាន់ខ្ពស់ផ្នែកគាំពារសង្គម។

មានប្រសាសន៍បើកវគ្គបណ្តុះបណ្តាល **ឯកឧត្តមអគ្គនាយករង** បានថ្លែងអំណរគុណចំពោះ ជំនាញការជាន់ខ្ពស់ផ្នែកគាំពារសង្គមរបស់អង្គការ ILO ដែលគាំទ្រវគ្គបណ្តុះបណ្តាលនេះ ដែលនេះជាការពង្រឹងសមត្ថភាពចំណេះដឹងមន្ត្រី បុគ្គលិកបេឡាជាតិសន្តិសុខសង្គម ហើយក៏ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្សរបស់ស្ថាប័ន ប.ស.ស. ដើម្បីឱ្យមន្ត្រី និងបុគ្គលិកមានសមត្ថភាពអាចសហការជាមួយអន្តរជាតិធ្វើការវិភាគវាយតម្លៃហិរញ្ញវត្ថុលើម៉ូដែលផ្សេងៗ នៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ឈរលើទិន្នន័យបែបវិទ្យាសាស្ត្រ។

ក្នុងឱកាសជាមួយគ្នា **ឯកឧត្តមអគ្គនាយករង** ក៏បានស្នើដល់សិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់ ប្រឹងប្រែងរៀនសូត្រឱ្យអស់ពីសមត្ថភាព ដើម្បីអាចក្លាយជាអ្នកជំនាញការដ៏ពិតប្រាកដមានសមត្ថភាពពេញលេញ ដែលអាចបំពេញតម្រូវការស្ថាប័ន វិភាគវាយតម្លៃហិរញ្ញវត្ថុច្បាស់លាស់ លើកំណែទម្រង់នានា នៃរបបសន្តិសុខសង្គម រួមទាំងគន្លឹះសំខាន់ក្នុងវាយតម្លៃហិរញ្ញវត្ថុផ្សេងៗទៀតរបស់ស្ថាប័នផងដែរ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៥ ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាល ប.ស.ស. ដោយមានការចូលរួមពីក្រុមការងារវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃ ប.ស.ស. មន្ត្រីបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងតំណាងអង្គការអន្តរជាតិខាងការងារ (ILO) សរុបប្រមាណជា ២៣រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# វគ្គបណ្តុះបណ្តាលស្តីពី ម៉ូដែលសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន ត្រូវបានបញ្ចប់ដោយជោគជ័យ

## កម្រងរូបភាពសកម្មភាព



ក្នុងដំណើរការរយៈពេល៣ថ្ងៃកន្លងមក វគ្គបណ្តុះបណ្តាលស្តីពី ម៉ូដែលសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន (ILO-Pens Modelling) ត្រូវបានបិទបញ្ចប់ដោយជោគជ័យ ក្រោមអធិបតីភាព **ឯកឧត្តម ឃុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃពុធ ទី១០ ខែកញ្ញា ឆ្នាំ២០២៥ នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

មានប្រសាសន៍ក្នុងឱកាសបិទវគ្គបណ្តុះបណ្តាលខាងលើ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. សង្ឃឹម និងជឿជាក់ថា សិក្ខាកាមទាំងអស់នឹងយកចំណេះដឹងដែលទទួលបានពីការសិក្សានេះ ទៅពង្រីកសមត្ថភាពខ្លួន និងអង្គភាពឱ្យកាន់តែប្រសើរថែមទៀតជាក់ជាមិនខាន ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ ទទួលបានការគាំទ្រពីអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងក្រុមការងារបច្ចេកទេសក្នុងការវិភាគហានិភ័យហិរញ្ញវត្ថុនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដែលប្រើប្រាស់គំរូនិទស្សន៍ដែលបង្កើតដោយអង្គការអន្តរជាតិខាងការងារ (ILO)៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ លើនីតិវិធីនៃការចុះបញ្ជីសហគ្រាស និងកម្មករនិយោជិត និងការបង់ភាគទាន តាមប្រព័ន្ធបច្ចេកវិទ្យា

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ តំណាងក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងសមាគម ប្រមាណជា ១០០រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើនីតិវិធីនៃការចុះបញ្ជីសហគ្រាស និងកម្មករនិយោជិត និងការបង់ភាគទានមកក្នុងបេឡាជាតិសន្តិសុខសង្គម ក្រោមអធិបតីភាព **ឯកឧត្តម ឃុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

មានប្រសាសន៍បើកសិក្ខាសាលា **ឯកឧត្តមអគ្គនាយករង** បានថ្លែងឡើងថា ប.ស.ស. បានដើរតួនាទីយ៉ាងបុរេសកម្មសម្រាប់បម្រើសេវាដល់សមាជិក ដែលបច្ចុប្បន្ន ប.ស.ស. បាននិងកំពុងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគ្រប់ទម្រង់ ជាក់ស្តែងដូចប្រព័ន្ធចុះបញ្ជីសហគ្រាស និងកម្មករនិយោជិត និងបង់ភាគទាន ដែលនឹងផ្តល់ភាពងាយស្រួល ឆាប់រហ័សដល់ម្ចាស់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន នៅពេលដំណើរការសហគ្រាសថ្មី បង់ភាគទានប្រចាំខែ និងចុះបញ្ជីបងប្អូនកម្មករនិយោជិតចូលបម្រើការងារភ្លាមៗ មកក្នុងប្រព័ន្ធ ប.ស.ស. ដើម្បីកំណត់អត្តសញ្ញាណដោយពុំចាំបាច់មកដោយផ្ទាល់នោះទេ។

**ឯកឧត្តមអគ្គនាយករង** បានបន្ថែមថា ដើម្បីឱ្យប្រព័ន្ធបច្ចេកវិទ្យាមានភាពគ្រប់ជ្រុងជ្រោយ ទាមទារឱ្យសិក្ខាកាមទាំងអស់ចូលរួមផ្តល់ធាតុចូលឱ្យបានផុសផុល ដើម្បីធានាបានថា គ្រប់កម្មករនិយោជិតទាំងអស់ត្រូវតែទទួលបានការគ្របដណ្តប់ដោយ របបសន្តិ-សុខសង្គម ដែលជាអត្ថប្រយោជន៍ និងសិទ្ធិដែលពួកគាត់ត្រូវទទួលបាន តាមរយៈការអនុវត្តប្រព័ន្ធបច្ចេកវិទ្យា។

**ឯកឧត្តមអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា អង្គសិក្ខាសាលា នឹងផ្តល់ធាតុចូលដើម្បីជាប្រយោជន៍សម្រាប់ការអភិវឌ្ឍនូវប្រព័ន្ធបច្ចេកវិទ្យារបស់ ប.ស.ស. ឱ្យកាន់តែរីកចម្រើន ដើម្បីក្លាយជាប្រព័ន្ធមួយសម្រាប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន អាចទទួលបានភាពងាយស្រួល ឆាប់រហ័ស និងត្រឹមត្រូវ។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចសហការល្អក្នុងភាពជាដៃគូរវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាល ជាអត្ថប្រយោជន៍យ៉ាងសំខាន់របស់សមាជិក ប.ស.ស.

## កម្រងរូបភាពសកម្មភាព












នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥ តំណាងក្រសួងសុខាភិបាល តំណាងទីភ្នាក់ជាតិបញ្ជាក់ចំណាយតំណាងការិយាល័យស្រុកប្រតិបត្តិ និងតំណាងមូលដ្ឋានសុខាភិបាលរដ្ឋ និងឯកជនក្នុងរាជធានីភ្នំពេញ ដែលជាដៃគូផ្តល់សេវាជូនសមាជិក ប.ស.ស. ប្រមាណជា ១៥០រូប បានចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ និងពង្រឹងភាពជាដៃគូរវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាល ដែលរៀបចំឡើងនៅទីស្នាក់ការកណ្តាល ប.ស.ស. ក្រោមអធិបតីភាព **ឯកឧត្តម ឃុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មានប្រសាសន៍ក្នុងកម្មវិធីបើកសិក្ខាសាលា **ឯកឧត្តមអគ្គនាយករង** បានថ្លែងឡើងថា បច្ចុប្បន្នសមាជិក ប.ស.ស. បានកើនឡើងដល់ជាង ៣,៣លាននាក់ ដែលតម្រូវការប្រើប្រាស់សេវានៅតាមមន្ទីរពេទ្យនឹងមានកើនឡើងផងដែរ ដូចនេះកិច្ចសហការល្អរវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាលដៃគូ នឹងជួយធានាដល់ការផ្តល់សេវាជូនសមាជិក ប.ស.ស. ដោយរលូន និងកាន់តែប្រសើរ។ សិក្ខាសាលា រៀបចំឡើងក្នុងន័យបើកឱកាសជូនភាគីពាក់ព័ន្ធលើកពីបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយជាមួយគ្នាសំដៅធានាបាននូវកិច្ចសហការល្អ។

តាមរយៈសិក្ខាសាលា **ឯកឧត្តមអគ្គនាយករង** បានបញ្ជាក់យ៉ាងច្បាស់ថា ប.ស.ស. នឹងបន្តយន្តការទូទាត់ថ្លៃព្យាបាលរបស់សមាជិក ប.ស.ស. ជូនមូលដ្ឋានសុខាភិបាលឱ្យបានកាន់តែឆាប់រហ័ស តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាកាន់តែទំនើប ក្នុងស្មារតីជាដៃគូល្អ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋានសុខាភិបាលដៃគូ ប៉ុន្តែទន្ទឹមនេះ មូលដ្ឋានសុខាភិបាលដៃគូ ត្រូវប្រកាន់ខ្ជាប់នូវជំហរជាដៃគូល្អ ក្នុងកាការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព និងកាន់តែប្រសើរជូនដល់សមាជិក ប.ស.ស.។

ក្នុងសិក្ខាសាលានេះ **ឯកឧត្តមអគ្គនាយករង** រំពឹងយ៉ាងមុតមាំថា រវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាលដៃគូ ត្រូវបង្ហាញពីក្តីកង្វល់ និងបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះក្នុងភាពជាដៃគូ ល្អ ជាពិសេសផ្តល់មតិយោបល់ស្ថាបនា គាំទ្រឱ្យគ្នាទៅវិញទៅមក និងរួមគ្នាដោះស្រាយបញ្ហា ដើម្បីធានាឱ្យបាននូវឧត្តមប្រយោជន៍ ដល់ សមាជិក ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.







☛មានប័ណ្ណ ប.ស ស. ហើយ
តែថៅកែរបស់អ្នកមិនបង់ភាគទានឱ្យអ្នក
មែនទេ?



☛បើគ្មាន ប.ស.ស. ទេ!
ប្រហែលបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ
ខ្ញុំមិនបានទៅលេងម៉ែនៅស្រុកទេ




☛អស់លទ្ធភាពបង់ភាគទាន
តើត្រូវធ្វើដូចម្ដេច?




☛ឥឡូវនេះ សមាជិក ប.ស.ស.
ទាំងអស់អាចដាក់ឯកសារទាមទារ
តាវកាលិក



☛ពេលនេះខ្ញុំទើបយល់ច្បាស់ ថាប័ណ្ណ
ប.ស.ស.
ពិតជាមានតម្លៃណាស់សម្រាប់គ្រួសារខ្ញុំ




☛ប្រាកដណាស់! នៅពេលអ្នកចាស់
ធ្វើការលែងកើតនោះអ្នកនឹងទទួលបាន
ប្រាក់សោធន (ប្រាក់ចូលនិវត្តន៍
ឬប្រាក់រ៉ឺត្រែត) ពី ប.ស.ស.!

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.




សាខា ប.ស.ស. នៅផ្សារទំនើបអ៊ីអន ម៉ល (AEON - MALL) ទាំង ៣ទីតាំង ក្នុងរាជធានីភ្នំពេញ បើកបម្រើការងារពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ២២:០០នាទីយប់ លើកលែងតែថ្ងៃបុណ្យជាតិ។

លោកអ្នកអាចទទួលបានសេវាដូចជា៖

- ✍ ធ្វើប័ណ្ណសមាជិក ប.ស.ស.
- ✍ ដាក់របាយការណ៍គ្រោះថ្នាក់ការងារ
- ✍ ស្នើសុំលិខិតព្យាបាលបន្ត
- ✍ ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់ស្ត្រីមានផ្ទៃពោះ
- ✍ ស្នើសុំប្រាក់បំណាច់ប្រចាំថ្ងៃ និងប្រាក់បំណាច់លំហែមាតុភាព
- ✍ ស្នើសុំប្រាក់សោធន

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!




សម្រាប់សមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ទាំងអស់ អាចបង់ភាគទានមក ប.ស.ស. ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ នៃរៀងរាល់ខែ តាមរយៈធនាគារដៃគូ ប.ស.ស. ដែលរួមមាន ៖

- ✍ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK PLC. )
- ✍ ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA BANK)
- ✍ ធនាគារ កាណាឌីយ៉ា ក.អ (CANADIA BANK PLC.)
- ✍ ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB Bank Cambodia)
- ✍ ធនាគារ ភ្នំពេញ ពាណិជ្ជ (PPCBank)

✍ ចំណាំ៖ សម្រាប់ការបង់ភាគទាន មក ប.ស.ស. គឺធ្វើឡើងតាមរយៈកម្មវិធីទូរសព្ទដៃធនាគារដៃគូ ខាងលើ ឬអញ្ជើញទៅកាន់ធនាគារដៃគូខាងលើដោយផ្ទាល់។

⚠ សូមប្រយ័ត្ន៖ ចំពោះការបង់ភាគទានតាមរយៈ QR CODE ឬតាមរយៈវិធីផ្សេងៗ ដែលមានឈ្មោះបុគ្គល គឺជាករណីឆបោក សូមបងប្អូនមេត្តាប្រុងប្រយ័ត្នឱ្យបានខ្ពស់ ជៀសវាងខាតបង់ថវិកាផ្ទាល់ខ្លួន។

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.

✍ ចំណាំ៖ ក្នុងករណីលោកអ្នកសង្កេតឃើញថា ក្រុមហ៊ុនរបស់អ្នកប្រកាសប្រាក់ឈ្នួលមក ប.ស.ស. មិនត្រឹមត្រូវ កាត់ប្រាក់ឈ្នួលរបស់អ្នកសម្រាប់ការបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ឬមិនបង់ភាគទានផ្នែកប្រាក់សោធន ឬមិនស្នើសុំប័ណ្ណ ប.ស.ស. សម្រាប់អ្នក សូមលោកអ្នករាយការណ៍មក ប.ស.ស. ភ្លាមៗតាមរយៈ

- ? ប្រអប់បណ្តឹងអនាមិក (https://feedback.mlvt.gov.kh/feedback)
- ? ប្រអប់សារ Facebook page ផ្លូវការរបស់ ប.ស.ស.
- ? ឬទាក់ទងមកលេខ ១២៨៦

⚠ បញ្ជាក់៖ រាល់ម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមិនអនុវត្តកាតព្វកិច្ចបង់ភាគទានជូននិយោជិតរបស់ខ្លួន នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីរបបសន្តិសុខសង្គមជាធរមាន។

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!







សម្រាប់សមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ (អ្នកប្រកបរបរផ្ទាល់ខ្លួន) និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. មានសិទ្ធិប្រើប្រាស់សេវាផ្នែកថែទាំសុខភាពនៅមន្ទីរពេទ្យដៃគូ ប.ស.ស. ឥតគិតថ្លៃ ដោយត្រូវមានភាគទានជាប់ពី ២ខែជាប់គ្នាឡើងទៅ។

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.

ពិតមែនហើយ! បុគ្គលិក ឬកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. និងមានប័ណ្ណ ប.ស.ស. ដែលមានសុពលភាព នៅពេលឈឺ ឬមានគ្រោះថ្នាក់ក្រៅម៉ោងការងារ នឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- ទទួលបានការរ៉ាប់រងលើថ្លៃព្យាបាល និងថែទាំសុខភាពដោយឥតបង់ថ្លៃ
- ទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ៧០% (សម្រាកព្យាបាលចាប់ពី ៨ថ្ងៃឡើងទៅ)
- ទទួលបានប្រាក់ឧបត្ថម្ភចំនួន ២លានរៀល ក្នុងករណីឈឺរហូតទទួលមរណភាព
- លើសពីនេះ សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះនឹងទទួលបានអត្ថប្រយោជន៍ដូចជា៖

➤ សេវាសម្រាល សេវាថែទាំមុន និងក្រោយពេលសម្រាល ដោយឥតគិតថ្លៃ

➤ប្រាក់បំណាច់មាតុភាពចំនួន ៩០ថ្ងៃ (បានបង់ភាគទានមក ប.ស.ស. បានយ៉ាងតិច ៩ខែក្នុងអំឡុងពេល ១២ខែចុងក្រោយគិតមកដល់ខែសម្រាលកូន)

➤ ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល

☎ សម្រាប់ផ្តល់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខ ១២៨៦ !!







✦ប្រសិនបើលោកអ្នកផ្លាស់ប្តូរការងារថ្មី នោះមិនតម្រូវឱ្យប្តូរប័ណ្ណសមាជិក ប.ស.ស. ថ្មីនោះទេ ដោយលោកអ្នកគ្រាន់តែបង្ហាញប័ណ្ណសមាជិក ប.ស.ស. ចាស់របស់អ្នក ទៅឱ្យរដ្ឋបាលក្រុមហ៊ុន រោងចក្រ សហគ្រាសថ្មី និងបញ្ចូលលេខអត្តសញ្ញាណ ប.ស.ស. ដែលមាននៅលើប័ណ្ណ និងបង់ភាគទានបន្តមក ប.ស.ស. ជាការស្រេច។

☎ សម្រាប់ផ្តល់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខ ១២៨៦ !!




✦សាខា ប.ស.ស. នៅផ្សារទំនើបអ៊ីអន ម៉ល (AEON MALL) ទាំង ៣ទីតាំង ក្នុងរាជធានីភ្នំពេញ បើកបម្រើការងារពី ថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ២២:០០នាទីយប់ លើកលែងតែថ្ងៃបុណ្យជាតិ។

លោកអ្នកអាចទទួលបានសេវាដូចជា៖

- ធ្វើប័ណ្ណសមាជិក ប.ស.ស.
- ដាក់របាយការណ៍គ្រោះថ្នាក់ការងារ
- ស្នើសុំលិខិតព្យាបាលបន្ត
- ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់ស្ត្រីមានផ្ទៃពោះ
- ស្នើសុំប្រាក់បំណាច់ប្រចាំថ្ងៃ និងប្រាក់បំណាច់លំហែមាតុភាព
- ស្នើសុំប្រាក់សោធន

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# យើងខ្ញុំតែងតែស្តាប់លោកអ្នក ដើម្បីកែលម្អឱ្យកាន់តែប្រសើរ!



## សូមកុំស្ទាក់ស្ទើរ! តើលោកអ្នកមានសំណួរទាក់ទងនឹង ប.ស.ស. មែនទេ?
## មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទរបស់បេឡាជាតិសន្តិសុខសង្គម ១២៨៦

**បេឡាជាតិសន្តិសុខសង្គម ប.ស.ស. គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។**




ដើម្បីបង្កលក្ខណៈងាយស្រួលដល់សមាជិក ប.ស.ស. ក្នុងការទំនាក់ទំនង និងសាក់សួរព័ត៌មាន ឬសេវាផ្សេងៗ របស់ ប.ស.ស. លោក លោកស្រី អាច ទំនាក់ទំនងតាមរយៈលេខទូរសព្ទ Call Center ១២៨៦ ដោយឥតគិតថ្លៃ ឬតាម បណ្តាញសង្គមផ្លូវការរបស់ ប.ស.ស.។

ការិយាល័យសេវាអតិថិជន នៃនាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនង សាធារណៈ នៃ ប.ស.ស. គឺជាមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Call Center 1286) ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក។

### ការិយាល័យសេវាអតិថិជន នៃនាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ៖

- ទទួលព័ត៌មានពីសមាជិក ប.ស.ស. មជ្ឈដ្ឋានទូទៅ និងព័ត៌មានផ្សេងៗ
- ទទួលព័ត៌មានពីសមាជិកទៅឱ្យនាយកដ្ឋានជំនាញ ពិនិត្យដោះស្រាយ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលា
- ផ្តល់ព័ត៌មានអំពីច្បាប់ដែលទាក់ទងអំពីកិច្ចដំណើរការ ការគណនា ការបង់ភាគទាន ការលើកថ្ងៃដាក់ឯកសារ អត្រាប្តូរប្រាក់ និងព័ត៌មានផ្សេងៗ
- សម្របសម្រួលការផ្តល់សេវាជូនសមាជិក ប.ស.ស.
- ផ្តល់សេវាមគ្គុទេសក៍ដល់សាធារណៈជនមកស្វែងយល់ អំពីប្រព័ន្ធសន្តិសុខសង្គម ជាដើម៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

**អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍**

General Department of Information and Broadcasting

លេខ : ០៤៤ ព.ស-ផ.អ

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥

# លិខិតអនុញ្ញាត

**យោង ៖** -ប្រកាសលេខ ១០៨ ប្រក.ព.ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងព័ត៌មាន

-លិខិតលេខ ៤១០/២២ .ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ

-លិខិតស្នើសុំប្តូរឈ្មោះ និងទីតាំង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម។

តាមសេចក្តីដូចមានចែងក្នុងយោងខាងលើ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ជ្រាបថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន អនុញ្ញាតឱ្យព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ប្តូរឈ្មោះមកជាព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. និងមានអាសយដ្ឋានទីស្នាក់ការថ្មីស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្តលិខិតលេខ ៤១០/២២-ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ក្នុងដំណើរការផ្សព្វផ្សាយ ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាស របស់ក្រសួងព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ករណីប្រព្រឹត្តល្មើស សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ០១ (មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ត្រូវស្នើសុំបន្តសុពលភាពដើម្បីធ្វើសកម្មភាពការងារលើវិស័យព័ត៌មាន និងសោតទស្សន៍ មុនផុតកំណត់រយៈពេល ៣០ (សាមសិប) ថ្ងៃ។

**អគ្គនាយក**

**ផុស_សុវណ្ណ**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- អគ្គស្នងការនគរបាលជាតិ
- និយ័តករទូរគមនាគមន៍កម្ពុជា
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ

" ដើម្បីជូនជ្រាប "

- ឯកសារ កាលប្បវត្តិ